# សេចក្តីជូនដំណឹងស្តីពីការលក់ដេញថ្លៃរថយន្ត

អង្គការអន្តរជាតិបំរើសុខភាពប្រជាជន ការិយាល័យប្រចាំប្រទេសកម្ពុជា(PSI Cambodia) យើងខ្ញុំ ត្រូវការដាក់លក់អោយដេញថ្លៃរថយន្តចំនួន បួន(៤)គ្រឿង មានលក្ខណះពិសេសដូចខាងក្រោមៈ

| លរ | ម៉ាករថយន្ត | ប្រភេទឡាន | ឆ្នាំផលិត | ពណ៌រថយន្ត | ផ្លាកលេខរថយន្ត |
|---|---|---|---|---|---|
| ១ | FORD EXPLORER (ម៉ាស៊ូត) | គ្មានពន្ធនាំចូល | ២០០២ | ស | ONG 1 2-0592 |
| ២ | FORD RANGER (ម៉ាស៊ូត) | គ្មានពន្ធនាំចូល | ២០០៥ | ស | ONG 1 2-0574 |
| ៣ | FORD RANGER (ម៉ាស៊ូត) | ពន្ធនាំចូល | ២០០៨ | ស | ONG 1 2-0551 |
| ៤ | FORD RANGER (ម៉ាស៊ូត) | ពន្ធនាំចូល | ២០០៨ | ស | ONG 1 2-0577 |

## 1. លក្ខខណ្ឌនៃការលក់

- រថយន្តទាំងអស់ ត្រូវបានដាក់អោយដេញថ្លៃជាសាធារណៈក្នុងលក្ខណៈពិសេសដូចរៀបរាប់ខាងលើ និង ក្នុងស្ថានភាពបច្ចុប្បន្ន ដោយគ្មានការធានាលើការខូចខាតឬតម្រូវសម្ភារះអ្វីទាំងអស់។ ហេតុដូចនេះ អ្នកអ្នកចូលរួមដេញថ្លៃ ត្រូវមកធ្វើការត្រួតពិនិត្យរថយន្តផ្ទាល់ក្នុងទីតាំងចំណត និង សាកសួរព័តមានឲ្យបានច្បាស់លាស់ មុននឹងដាក់ទំរង់តំលៃដេញថ្លៃ។
- ដើម្បីត្រួតពិនិត្យរថយន្តផ្ទាល់ក្នុងទីតាំងចំណត សូមទាក់ទងលោក កែវ សារ៉េត តាមរយៈទូរសព្ទ័លេខ 011 857 373 ពីថ្ងៃទី ៣ ដល់ ១២ ខែមីនា (ថ្ងៃចន្ទ ដល់ សុក្រ) ចាប់ពីម៉ោង ៩ព្រឹក រហូតដល់ ៥ល្ងាច។
- ទំរង់តំលៃដេញថ្លៃៈ
  - អ្នកអាចទទួលយកទំរង់ដេញថ្លៃ ដោយឥតគិតថ្លៃពីបុគ្គលិកផ្នែកទទួលភ្ញៀវ នៅការិយាល័យ PSI Cambodia ដែលស្ថិតនៅទីតាំង ផ្ទះលេខ ១៦០ ផ្លូវ៧១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ដោយផ្ទាល់(ក្នុងម៉ោងនិងថ្ងៃធ្វើការ)។
  - ឬ អ៊ីម៉ែលមកកាន់ procurement@psi.org.kh។
- ការដេញថ្លៃនេះ ត្រូវបានកំណត់តម្លៃចាប់ផ្តើមទាបបំផុត <u>USD2,500 (ក្នុង១គ្រឿង)</u>។ ទំរង់តំលៃដេញ ១ច្បាប់អនុញ្ញាត ដេញថ្លៃសម្រាប់រថយន្ត ១គ្រឿងប៉ុណ្ណោះ។
- អ្នកដែលចូលរួមដេញថ្លៃ តម្រូវអោយតម្កល់ប្រាក់ចំនួន 200ដុល្លារ(១ទំរង់)។ ប្រាក់កក់នេះនឹងបង្វិលសងវិញសម្រាប់អ្នកដែលមិនបានទទួលជោគជ័យក្នុងការដេញថ្លៃ។ សំរាប់អ្នកឈ្នះក្នុងការដេញថ្លៃ ប្រាក់កក់នេះនឹងធ្វើការទូទាត់ជាមួយតំលៃដេញថ្លៃ ប៉ុន្តែក្នុងករណីបដិសេធមិនទទួលយកការដេញថ្លៃប្រាក់កក់នេះនឹងត្រូវចាត់ទុកជាអាសារបង់ ។
- អ្នកឈ្នះក្នុងការដេញថ្លៃតម្រូវអោយទូទាត់ថ្លៃរថយន្តក្នុងរយះពេល ១០ថ្ងៃធ្វើការបន្ទាប់ពីទទួលបានដំណឹង និងចុះកិច្ចសន្យាទិញលក់។
- អ្នកឈ្នះក្នុងការដេញថ្លៃ ត្រូវរៀបចំសំណុំបែបបទ និងកាតព្វកិច្ចបង់ពន្ធ អនុឡោមតាមគោលការណ៍របស់គយនិងពន្ធដាររួចរាល់ មុនពេលបន្តការផ្ទេរកម្មសិទ្ធិ និងយករថយន្តចេញពីទីតាំងចំណតរបស់អង្គការPSIបាន។ រាល់ការចំណាយជាបន្ទុករបស់អ្នកទិញ។

## 2. ទីតាំង និង កាលបរិច្ឆេទឈប់ទទួលពាក្យ

ទំរង់ដេញថ្លៃ នឹងឈប់ទទួលនៅថ្ងៃទី **១៣ ខែមីនា ឆ្នាំ ២០២៥ វេលាម៉ោង ៤ ល្ងាចជាកំហិត។**

“**ទំរង់តំលៃដេញថ្លៃ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត**” នឹងយកមកដាក់នៅទីតាំងការិយាល័យរបស់អង្គការ PSI Cambodia ផ្ទាល់ដែលស្ថិតនៅទីតាំង ផ្ទះលេខ១១៦០ ផ្លូវ៧១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ។ អ្នកចូលរួមតម្រូវឲ្យបង់ប្រាក់តម្កល់ និងភ្ជាប់ជាមួយអត្តសញ្ញាបណ្ណថតចម្លង១ច្បាប់។

ចំពោះព័ត៌មានបន្ថែម សូមទំនាក់ទំនងបុគ្គលិកផ្នែកលទ្ធកម្ម តាមរយៈ ទូរសព្ទ័លេខ(៨៥៥ ២៣)៩៨៧ ៩០៥ ឬ ២១៨ ៨៩៦ អ៊ីម៉ែល Procurement@psi.org.kh ។

## 3. ការវាយតម្លៃ

ក្នុងដំណើរការបើកតំលៃដេញថ្លៃ វត្តមានអ្នកដែលអាចចូលរួមគឺមានតែគណៈកម្មាធិការដេញថ្លៃ នៃអង្គការប៉ុណ្ណោះ។ ការដេញថ្លៃ នឹងត្រូវបានវាយតម្លៃតាមលក្ខណៈដូចខាងក្រោមៈ

- ដាក់ទំរង់ដេញថ្លៃ ក្នុងស្រោមសំបុត្របិទជិត ដាក់បានមុនថ្ងៃឬម៉ោងកំណត់ (ដាក់ពាក្យតាមរយៈអ៊ីម៉ែល ដាក់ទំរង់យឺតយ៉ាវ និងមិនគ្រប់លក្ខខណ្ឌត្រូវបានបដិសេធ)
- យើងខ្ញុំ នឹងផ្តល់អទិភាពឈ្នះ ជូនអ្នកដែលហ៊ានអោយតំលៃខ្ពស់ជាងគេក្នុង១គ្រឿង ហើយនឹងអាចទិញថ្លៃជាកញ្ចប់។
- អង្គការយើងខ្ញុំ សូមរក្សាសិទ្ធិក្នុងការលុបចោលការប្រគល់ការដេញថ្លៃជូនដល់ អ្នកដែលបានផ្តល់តំលៃខ្ពស់ជាងក្នុងករណីពាក់ព័ន្ធជំលោះអត្ថផលប្រយោជន៍។

## 4. ការប្រកាសលទ្ធផល

អ្នកឈ្នះ នឹងត្រូវជូនដំណឹងក្នុងរយះពេល ១សប្តាហ៍បន្ទាប់ តាមរយៈទូរស័ព្ទ។

សូមរក្សាសិទ្ធក្នុងការកែរប្រែ ក្នុងករណីមានហេតុកើតឡើងដោយឥតបានព្រៀងទុក។